- ពិភាក្សា សំរបសំរួលជាមួយភាគីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីជ្រើសរើសរកសហគ្រិន ដែលមានស្នាដៃល្អក្នុងការងារសំរាប់ផ្តល់ជូនឈ្មោះកីឡា ។
- ត្រួតពិនិត្យដំណើរការផ្តល់ជូលប្បរិកីឡា និង រាយការណ៍អំពីការងារសំរេចបាន ជូនរាជរដ្ឋាភិបាល ។

ប្រការ ៣ : គណៈកម្មការនេះមានសិទ្ធិបង្កើតអនុគណៈកម្មាការមួយចំនួន ដើម្បីជាជំនួយការងារ និងមានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ។

ប្រការ ៤ : សមាជិករបស់គណៈកម្មាការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៥ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹង សេចក្តីសំរេចនេះទុកជានិរាករណ៍ ។

ប្រការ ៦ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និងឯកឧត្តម លោកជំទាវ អស់លោក ដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

***

រាជធានីភ្នំពេញ ,ថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៣២ សសរ

## ស្តីពីការបន្ថែមសមាសភាពនៅក្នុងគណៈកម្មការសំរាប់ដោះស្រាយ បញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ០៧/សសរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា
- តាមសំណើរប្រធានគណៈកម្មការសំរាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

## សំរេច

ប្រការ ១ : ត្រូវបានបន្ថែម សមាសភាពនៅក្នុងគណៈកម្មការសំរាប់ដោះស្រាយបញ្ហាពួជកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ដែលមាននាយនាមដូចខាងក្រោម ៖

១-ឯកឧត្តម ពៅ យាំដា អនុរដ្ឋលេខាធិការ ក្រសួងពត៌មាន ជាសមាជិក

២-ឯកឧត្តម អ៊ុំ ម៉ុនធឿន អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ជាសមាជិក

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ ខេត្ត-ក្រុង និង សាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមាន ប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★